គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា
Committee for Free and Fair Elections in Cambodia
ខុមហ្វ្រែល COMFREL

ថ្ងៃសុក្រ ៩រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី៥ ខែមករា ឆ្នាំ២០២៤

# សេចក្តីជូនដំណឹង

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល) សូមជម្រាប និងជូនដំណឹងដល់អ្នកសារព័ត៌មាន និងសាធារណៈជនទាំងអស់ឱ្យបានជ្រាបថា ខុមហ្វ្រែលនឹងរៀបចំកិច្ចពិភាក្សាស្តីពី«**ការឆ្លុះបញ្ចាំងបញ្ហាប្រឈម និងអនុសាសន៍ទាក់ទងនឹងដំណើរការបោះឆ្នោតឆ្នាំ២០២៣**»។ កិច្ចពិភាក្សានេះរៀបចំក្នុងគោលបំណង៖

- នាំភាគីពាក់ព័ន្ធការបោះឆ្នោតថ្នាក់ក្រោមជាតិធ្វើការចែករំលែក មតិយោបល់របស់ពួកគេអំពីឧបសគ្គ ឬបញ្ហាប្រឈម និងផ្តល់អនុសាសន៍ ចំពោះការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រកន្លងមក
- ប្រមូលមតិយោបល់ពីភាគីពាក់ព័ន្ធថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ ចងក្រងជា អនុសាសន៍ ទាក់ទងការបោះឆ្នោតកន្លងមក ដាក់ជូនភាគីពាក់ព័ន្ធជាពិសេសកម្រិតថ្នាក់សម្រេចចិត្ត ដើម្បីឆ្លើយតបទៅនឹងសំណូមពរ សម្រាប់ការបោះឆ្នោតដោយសេរី និងយុត្តិធម៌
- បើកលំហនៃការជួបជុំ ជជែកពិភាក្សា ដើម្បីមានឱកាសស្វែងយល់ពីគ្នា ការទំនាក់ទំនងជាមួយអង្គការដៃគូ និងភាគីពាក់ព័ន្ធសម្រាប់ការបោះឆ្នោតផ្សេងៗទៀត ចូលរួមរៀបចំជាអនុសាសន៍រួមសម្រាប់កំណែទម្រង់ការបោះឆ្នោត។

**ពេលវេលា និងទីកន្លែង ៖**

1. ថ្ងៃទី១១ ខែមករា ឆ្នាំ២០២៤ ចាប់ពីម៉ោង ៨:០០នាទីព្រឹកតទៅ នៅខេត្តបន្ទាយមានជ័យ
2. ថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤ ចាប់ពីម៉ោង ៨:០០នាទីព្រឹកតទៅ នៅខេត្តកោះកុង
3. ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៤ ចាប់ពីម៉ោង ៨:០០នាទីព្រឹកតទៅ នៅខេត្តព្រះសីហនុ
4. ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៤ ចាប់ពីម៉ោង ៨:០០នាទីព្រឹកតទៅ នៅខេត្តឧត្តរមានជ័យ

អាស្រ័យដូចនេះ យើងខ្ញុំសូមគោរព ជូនដំណឹង និងអញ្ជើញលោក លោកស្រី អ្នកនាង កញ្ញា អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ មេត្តាជ្រាប និងចូលរួមយកព័ត៌មានឱ្យបានគ្រប់ៗគ្នា។

**សម្រាប់ព័ត៌មានបន្ថែម** / For more information, please contact:
កញ្ញា **ផន សុភីលាន** / Miss. Phorn Sophylian
ទូរស័ព្ទ / Tel: 089 923 867 (signal or Telegram)

**ទស្សនៈវិស័យ** ៖ សង្គមប្រជាធិបតេយ្យដែលផ្តល់ផលប្រយោជន៍ទៅប្រជាពលរដ្ឋ។
**Vision:** A democratic society that bring benefits to people.